ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបាត់ដំបង
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៤៣៧/២២-០៥-២០១៩
សំណុំរឿងជំនុំជម្រះ
លេខ:៥៦៩/០៩-០៩-២០១៩
សាលក្រមព្រហ្មទណ្ឌ
លេខ: ២០៦ "ច"/១៦-០៣-២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅថ្ងៃអង្គារ ១០រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ។

### សមាសភាពជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

- លោក [redacted] ជាព្រះរាជអាជ្ញារង

### ក្រឡាបញ្ជីសវនាការ

- លោក [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៤៣៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០១៩ ដែលមានដូចខាងក្រោម ៖

**ជនជាប់ចោទ**

១- ឈ្មោះ[redacted] សីលា ហៅ ឡា ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត[redacted] ទីលំនៅ[redacted] ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ[redacted] (រស់) ប្រពន្ធឈ្មោះ[redacted] មានកូន០៥នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន (ក្រៅឃុំ) តាមដីកាបង្គាប់ឱ្យដោះលែងលេខ: ៩០៩ ត.ព្រ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ។

២- ឈ្មោះ [redacted] ហួង ភេទស្រី អាយុ២៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតភូមិ[redacted] ទីលំនៅបច្ចុប្បន្ន[redacted] ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) ប្តីឈ្មោះ [redacted] មានកូន០៥នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (ក្រៅឃុំ)

៣- ឈ្មោះ[redacted] ហឿ ភេទស្រី អាយុ៥៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតភូមិ[redacted] ទីលំនៅ បច្ចុប្បន្នភូមិ[redacted] ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (ស្លាប់) ប្តីឈ្មោះ [redacted] មានកូន០៤នាក់ ជានីតិជន



ស្កេនជាមួយ CamScanner

ទោសពីមុន ធ្លាប់ជាប់ពន្ធនាគាររយៈពេល៦ខែ ពីបទប៉ះពាល់កម្មសិទ្ធិ និងលួច កាលពីឆ្នាំ ២០០៧ និងជាប់ពន្ធនាគាររយៈពេល៧ខែ ពីបទលួច កាលពីឆ្នាំ២០១០ ។ (ក្រៅឃុំ)

ជាប់ចោទពីបទៈ លួចដោយហិង្សាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

ដោយមានលោក [redacted] ចាន់ដេត និងលោក [redacted] សំអឿន ជាសហមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

**ដើមបណ្តឹងរដ្ឋប្បវេណី**

១-ឈ្មោះ [redacted] ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតភូមិ [redacted] ទីលំនៅបច្ចុប្បន្នភូមិ [redacted] ប្រពន្ធឈ្មោះ [redacted] (រស់) មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (ស្លាប់) កម្រិតវប្បធម៌មិនបានរៀន ជានីតិជន ទោសពីមុន គ្មាន ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង១៥ និង៣០នាទី ជនជាប់ចោទឈ្មោះ [redacted] សីលា ហៅ ឡា ,ឈ្មោះ [redacted] ហួង ឈ្មោះ [redacted] ហឿ ហៅយាយម៉ៅ បានធ្វើសកម្មភាពដកដំឡូងរបស់ជនរងគ្រោះឈ្មោះ [redacted] នៅចំណុចភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង នៅពេលជនរងគ្រោះទៅទាន់ ពួកគេបានប្រើហិង្សាដោយទាញកាំបិតដេញកាប់ជនរងគ្រោះតែម្តង ។ ក្រោយមកជនរងគ្រោះប្តឹងទៅនគរបាលឱ្យធ្វើការឃាត់ខ្លួន និងដកហូតវត្ថុតាងមួយចំនួន ។

- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខៈ ១៥១៩ ដស.សព ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ។
- បានឃើញដីកាដំណោះស្រាយលេខៈ ៦២០ ដ.ផ.រ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។
- បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ៥១០១ ត.ព្រ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ប្រធានសាលាដំបូងខេត្តបាត់ដំបង ។

**នាពេលពិនាក្សាដេញដោល**

- ជនជាប់ចោទឈ្មោះ [redacted] សីលា ឈ្មោះ [redacted] ហួង និងឈ្មោះ [redacted] ហឿ វត្តមាន ។
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វត្តមាន ។
- សាក្សីឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] វត្តមាន ។
- លោក [redacted] ចាន់ដេត និងលោក [redacted] សំអឿន សហមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សីឡា ឈ្មោះ [redacted] ហួង និងឈ្មោះ [redacted] ហឿ វត្តមាន ។



ស្កេនជាមួយ CamScanner

- ជនជាប់ចោទឈ្មោះ [redacted] សីលា បានឆ្លើយថាៈ ខ្លួនមិនទទួលស្គាល់ការចោទប្រកាន់នោះទេ ។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ ជាថ្ងៃកើតហេតុនៃការចោទប្រកាន់ ខ្លួនមិនបានទៅដកដំឡូងទេ គឺពេលព្រឹក ខ្លួន និងប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] ហួង បានទៅដឹកដើមចេកពីចំណុចអក្សរតេ ពីបងថ្លៃរបស់ខ្លួនយកមកផ្ទះដើម្បីដាំ មកដល់ផ្ទះវិញម៉ោងប្រហែល៣រសៀល ខ្លួនដឹកគោចងនៅក្រោយផ្ទះ រួចក៏ឮសំឡេងម្តាយក្មេករបស់ខ្លួនឈ្មោះ [redacted] ហឿ ស្រែកថា "ជួយផង!" ខ្លួនក៏ចេញពីកន្លែងមើលគោមកកន្លែងម្តាយក្មេក ក៏បានជួបឈ្មោះ [redacted] ដោយមានសមត្ថកិច្ចប្រហែល៤ទៅ៥នាក់ មកជាមួយគ្នាផង ខ្លួនមិនដឹងពួកគេមកធ្វើអ្វីទេ ឃើញបែបនេះ ខ្លួនក៏ដេញថត ពួកគេក៏នាំគ្នាត្រលប់ទៅវិញអស់ទៅ ហើយខ្លួនក៏ត្រលប់មកផ្ទះវិញមក ។ ខ្លួនពុំមានអ្វីបញ្ជាក់ថា នៅថ្ងៃកើតហេតុ ខ្លួនបានទៅដឹកដើមចេកនោះទេ ។ ខ្លួនមិនចាំចម្លើយដែលខ្លួនបានឆ្លើយកាលពីនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងដំណាក់កាលចៅក្រមស៊ើបសួរនោះទេ ប៉ុន្តែនៅពេលនេះ ខ្លួនសូមបដិសេធចម្លើយនោះចោល ដោយសារពេលនោះ ខ្លួនជាប់ឃុំនៅស្នងការដ្ឋាន ខ្លួនភ័យ ចេះតែឆ្លើយៗទៅ ហើយពេលនេះ ខ្លួនសូមឆ្លើយការពិត ។ ខ្លួនស្គាល់ឈ្មោះ [redacted] ដោយសារធ្លាប់ឃើញគាត់ដឹកធ្យូងទៅមកៗមុខផ្ទះ ប៉ុន្តែខ្លួនមិនដឹងគាត់រស់នៅឯណាទេ ហើយក៏មិនដែលមានទំនាក់ទំនងជាមួយដែរ ។ សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល៧ព្រឹក នៅពេលខ្លួនបើកឡានថ្មៃដឹកដំឡូងចំនួន៣២ក្រប្ជច ប្រហែលជាង១តោន យកទៅលក់ ។ ដំឡូងនោះគឺ ខ្លួន , ប្រពន្ធ និងម្តាយក្មេករបស់ខ្លួនដកនៅចំការរបស់ខ្លួននៅក្រោយផ្ទះចម្ងាយប្រហែល៥០០ម៉ែត្រ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ ដកតាំងពីព្រឹក រហូតជិតដល់ល្ងាចបានប្រហែល៣០ក្រប្ជច ចំណែកថ្ងៃទី ១៧,១៨,១៩,២០ ខ្លួនមិនបានដកដំឡូងនោះទេ ។ នៅថ្ងៃទី១៥ ខ្លួនអត់នៅផ្ទះទេ ប៉ុន្តែខ្លួនដឹងរឿងខ្លះៗដែរ គឺមានគេមកព្យួរដំឡូងរបស់ខ្លួនចោលអស់៤ហិចតា ។ ពីមុនមកខ្លួនមិនមានទំនាស់ជាមួយឈ្មោះ [redacted] នោះទេ គឺមានទំនាស់តែជាមួយ ឧកញ៉ា [redacted] ប៉ុណ្ណោះ ។

- ជនជាប់ចោទឈ្មោះ [redacted] ហួង បានឆ្លើយថាៈ ខ្លួនត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] សីលា ។ នៅថ្ងៃទី១៧ រហូតដល់ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ ខ្លួនមិនបានទៅដកដំឡូងនោះទេ ។ នៅថ្ងៃទី១៦ ខ្លួនបានទៅដកដំឡូងជាមួយកូនតូចរបស់ខ្លួន ៣ ទៅ ៤ នាក់ នៅចំការរបស់ខ្លួនខាងក្រោយផ្ទះចម្ងាយប្រហែល៥០០ម៉ែត្រពីផ្ទះ ដោយខ្លួនជាអ្នកដក កូនៗជាអ្នកជួយរើស ចំណែកប្តីរបស់ខ្លួនមិនបានទៅទេ ព្រោះរវល់ដឹកបន្លែឱ្យគេ មិនសូវនៅផ្ទះទេ រីឯម្តាយរបស់ខ្លួនក៏មិនបានទៅដែរ ហើយនៅថ្ងៃនោះ ខ្លួនដកបានចំនួនជាង១០ក្រប្ជច និងរើសដំឡូងដែលនៅសេសសល់ពីឈ្មោះ [redacted] លួចដកកាលពីថ្ងៃទី១៥ សរុបទាំងអស់ចំនួន ៣៣ ក្រប្ជច តែមិនបានយកទៅលក់ទេ ដោយប្រមូលយកមកទុកនៅផ្ទះសិន រហូតដល់ថ្ងៃទី២១ ទើបខ្លួន និងប្តីយកដំឡូងនោះទៅលក់ ។ ដីនោះមានទំហំ៧ហិចតា តែដំឡូងនៅសល់តែជាង៣ហិចតាប៉ុណ្ណោះ ដោយសារកាលពីថ្ងៃទី១៥ ឈ្មោះ [redacted] លួចដក ។ ដំឡូងនោះ គឺខ្លួនជាអ្នកដាំ ដោយដាំដុះៗតាំងពី



ស្កេនជាមួយ CamScanner

ម្ដាយរបស់ខ្លួនទៅរស់នៅទីនោះ ។ កន្លងមកខ្លួនធ្លាប់ឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរម្ដងហើយ ហើយចម្លើយនោះគឺជាចម្លើយពិតទាំងអស់ មិនមានគេបង្ខំឱ្យឆ្លើយទេ ។ ដីនោះស្ថិតនៅភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ជារបស់ម្ដាយខ្លួនកាន់កាប់យូរមកហើយ និងមានបង្កាន់ដៃជាលិខិតបញ្ជាក់កម្មសិទ្ធិ ។

- ជនជាប់ចោទឈ្មោះ [redacted] ហឿ បានឆ្លើយថាៈ ខ្លួនធ្លាប់ឆ្លើយនៅចៅក្រមស៊ើបសួរម្ដងរួចមកហើយ ប៉ុន្តែខ្លួនសូមបដិសេធត្រង់ចំណុចដែលថា នៅថ្ងៃទី២០ ខ្លួនបានទៅដកដំឡូង និងត្រង់ចំណុចថា ខ្លួនប្រើហិង្សា និងលួចដកដំឡូងរបស់គេ ដោយសារអ្នកកត់ត្រាមិនបានកត់តាមអ្វីដែលខ្លួនបានប្រាប់ ។ ដំឡូងដែលសមត្ថកិច្ចឃាត់មានចំនួន៣២ក្របួច បានមកពីកូនរបស់ខ្លួនឈ្មោះ ស្រីហួង និងឈ្មោះ [redacted] ស៊ីលា និងអ្នកផ្សេងទៀតខ្លួនមិនចាំ បានទៅដកនៅចំការជាដីរបស់ខ្លួនខាងក្រោយផ្ទះ កាលពីថ្ងៃទី១៦ និងតាំងពីមុនហូរហែរហូតមក ប៉ុន្តែនៅថ្ងៃទី២០ មិនបានដកទេ ចំណែកខ្លួនមិនបានទៅដកនោះទេ ហើយក៏មិនបានឃើញអ្នកណាខ្លះដកនោះដែរ គឺគ្រាន់តែឃើញពួកគេបានទៅរួចពេលខ្លួនទៅមើលឃើញមានចំនួន៣២ការុង ។ ខ្លួនបានដាំដំឡូងតាំងពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៨ ក្នុងដីទំហំ៧ហិកតាកន្លះ ហើយគេក្ឈួរចោលអស់៤ហិកតាកន្លះ នៅសល់៣ហិចតា ។ ដីនោះខ្លួនមានឯកសារបញ្ជាក់ ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថាៈ ដំឡូងជារបស់ខ្លួនជាអ្នកដាំចំណែកដីនោះ គឺខ្លួនសុំឈ្មោះ [redacted] ដាំ ។ ខ្លួនទើបតែដាំមួយឆ្នាំប៉ុណ្ណោះ គឺដាំកាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ ។ ជនជាប់ចោទបានទៅដកដំឡូងនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ មានគ្នាបីនាក់គឺ អ្នកទាំងបីដែលកំពុងមានវត្តមាននេះ ហើយខ្លួនឃើញដោយផ្ទាល់ភ្នែក ដោយដំបូងខ្លួនជិះម៉ូតូទៅបីនាក់ ពេលទៅដល់ចំការ ឈ្មោះ [redacted] ហឿ ចេញពីចម្ការទាញកាំបិតដេញកាប់ពួកខ្លួនតែម្ដង តែកាប់មិនត្រូវទេ ដោយសារពួកខ្លួនរត់ បន្ទាប់មកនៅវេលាម៉ោងជាង៣ ពួកខ្លួនបានទៅម្ដងទៀត ដោយហៅសមត្ថកិច្ចទៅជាមួយផង បានឃើញពួកគាត់កំពុងដកដំឡូងទៀត ។ សមត្ថកិច្ចមិនឃាត់នៅថ្ងៃនោះទេ ដោយគាត់ថា រត់ឱ្យតែរួចខ្លួនសិនទៅ ចាំគេដឹកដំឡូងចេញ ចាំចាប់ ។ ខ្លួនមិនដឹងថាដីនោះមានទំនាស់នោះទេ ព្រោះដីរបស់គេមានម្ចាស់ ។ ដីនោះមានគេដាំដំឡូងពីមុនមក ប៉ុន្តែមិនមែនពួកគាត់ជាអ្នកដាំទេ គឺអ្នកផ្សេងទៅថៃបាត់ហើយ ហើយផ្អាក២ឆ្នាំខ្លួនក៏សុំគេដាំទៅ ។ ខ្លួនមិនឃើញមានផ្ទះ ឬ រោងនៅក្បែរនោះទេ ។ ខ្លួនដាំដំឡូងលើដីទំហំ៥ហិកតា ហើយត្រូវជនជាប់ចោទលួចដកអស់ប្រមាណជាង៣០ក្របួច ដែលដាក់លើឡាននោះ ចំពោះទំហំដីមិនដឹងអស់ទំហំប៉ុន្មានទេ ព្រោះមិនបានវាស់ ។ នៅក្នុងរឿងហេតុនេះ ខ្លួនទាមទារសំណងចំនួន ៥ ពាន់ដុល្លារ ។

- សាក្សីឈ្មោះ [redacted] បានឆ្លើយថាៈ ខ្លួនមិនជាប់សាច់ញាតិជាមួយឈ្មោះ [redacted] នោះទេ ។ ខ្លួនរស់នៅភូមិកុយវែង ប៉ុន្តែនៅឆ្ងាយពីកន្លែងកើតហេតុដែរ ។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ ខ្លួនបានទៅចម្ការដំឡូងនោះជាមួយឈ្មោះ [redacted] ផងដែរ ព្រោះខ្លួនដាំដំឡូងចូលហ៊ុនគ្នាជាមួយឈ្មោះ [redacted] ។ ក្នុងការដាំដំឡូងនេះ ខ្លួន



ស្កេនជាមួយ CamScanner

ចំណាយដើមទុនអស់ជាង៣លានរៀល ហើយពូជដំឡូងទិញគេមួយបាច់២ពាន់រៀល ។ នៅថ្ងៃកើតហេតុវេលាម៉ោង៣ ពួកខ្លួនបានទៅចម្ការដំឡូងនោះ ឃើញជនជាប់ចោទដកដំឡូងជាមួយកូនរបស់គាត់ ហើយពួកខ្លួនបានត្រលប់មកផ្ទះវិញ ទូរស័ព្ទហៅសមត្ថកិច្ចទៅជាមួយ បន្ទាប់មកវេលាម៉ោងប្រហែល៥ជាងល្ងាច ពួកខ្លួនបានទៅម្តងទៀត ទៅចូលមើលដំឡូង ហើយឈ្មោះ [redacted] បានកាន់ទូរស័ព្ទថត ហើយឈ្មោះ [redacted] ហឿ យកកាំបិតដេញកាប់ពួកខ្លួន ពួកខ្លួនក៏បានរត់តែម្តង ។ ដីនោះ គឺខ្លួនសុំឈ្មោះ ហែន [redacted] ដាំ ហើយទើបតែដាំឆ្នាំនេះឯង ដោយមិនទាន់បានប្រមូលផលផង ។ ពេលខ្លួនចូលទៅដាំ ដីនោះគឺជាដីទទេ មិនមានដាំអ្វីនោះទេ និងមិនមានរោងក្បែរនោះទេ មានតែរោងនៅឆ្ងាយពីចម្ការប្រហែល ៥០០ម៉ែត្រ ។

- សាក្សីឈ្មោះ [redacted] បានឆ្លើយថាៈ ខ្លួនត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] ។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ ខ្លួនមិនបានទៅជាមួយឈ្មោះ [redacted] នោះទេ ។

- សាក្សីឈ្មោះ [redacted] បានឆ្លើយថាៈ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ ម៉ោងប្រហែល៣កន្លះ ខ្លួនបានដើរទៅផ្លាស់គោនៅជិតកន្លែងកើតហេតុនោះ ស្រាប់តែឃើញសមត្ថកិច្ចមួយក្រុមដឹកនាំដោយឈ្មោះ [redacted] នៅជិតចំការដំឡូង ខ្លួនឆ្ងល់ក៏ដើរទៅមើលឃើញមានមនុស្សពីរនាក់ ឈ្មោះ [redacted] និងឈ្មោះ [redacted] ចូលទៅរកម្តាយរបស់ខ្លួនឈ្មោះ [redacted] ហឿ ស្រាប់តែម្តាយរបស់ខ្លួនស្រែកថា ជួយផង ។ ខ្លួនមិនបានឃើញម្តាយរបស់ខ្លួនកាន់កាំបិតដេញកាប់គេទេ ។ ដំឡូងនោះជារបស់ប្អូនរបស់ខ្លួន ។ ខ្លួនមិនមែនរស់នៅជាមួយជនជាប់ចោទទេ គឺរស់នៅផ្ទះជិតនោះ ។ ខ្លួនមិនបានឃើញឈ្មោះ [redacted] ហឿ ឈ្មោះ [redacted] សីលា ដកដំឡូងនោះទេ ។

- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាៈ ក្រោយពីបានពិនិត្យពិចារណាលើលទ្ធផលនៃការស៊ើបអង្កេត និងស៊ើបសួរ គ្រប់ដំណាក់កាលនៃនីតិវិធី ក៏ដូចជាលទ្ធផលនៃការពិភាក្សាដេញដោលនាពេលសវនាការរួចមក តំណាងអយ្យការពិនិត្យឃើញថា ពិតជាមានបទ លួចដោយហិង្សាមានស្ថានទម្ងន់ទោស ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] សីលា ភេទប្រុស អាយុ២៨ឆ្នាំ ឈ្មោះ [redacted] ហួង ភេទស្រី អាយុ២៦ឆ្នាំ និងឈ្មោះ [redacted] ហឿ ភេទស្រី អាយុ៦០ឆ្នាំ ប្រព្រឹត្តនៅភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីទី២០ ខែឧសភា ឆ្នាំ២០១៩ ប្រាកដមែន ភស្តុតាងដាក់បន្ទុករួមមាន ចម្លើយសារភាពរបស់ជនជាប់ចោទនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ នៅអយ្យការ និងនៅចៅក្រមស៊ើបសួរ ។ ចម្លើយដោះសាររបស់ជនជាប់ចោទក្នុងពេលសវនាការថា ខ្លួនមិនបានទៅដកដំឡូង និងកាប់ទៅលើជនរងគ្រោះ ហើយខ្លួនដកដំឡូងគឺគ្រាន់តែដកដំឡូងនៅលើដីរបស់ខ្លួនប៉ុណ្ណោះ គ្រាន់តែជាចម្លើយដោះសាដើម្បីឱ្យខ្លួនរួចផុតពីការចោទប្រកាន់ប៉ុណ្ណោះ ដោយចម្លើយនេះ មិនមានអ្វីជាសំអាងផ្ទុយទៅនឹងសាក្សី និងភស្តុតាងដែលប្រមូលបានដោយមន្ត្រីនគរបាលយុត្តិធម៌ និងនីតិវិធីស៊ើបអង្កេត និងស៊ើបសួរនោះទេ ។ ហេតុនេះគប្បីតុលាការច្រានចោលចម្លើយដោះសារបស់ជនជាប់ចោទទាំងបីនាក់នេះទុកជាអសារបង់ ហើយតំណាងអយ្យការប្តឹងសុំរក្សាបទចោទតាមដីកា



ស្កេនជាមួយ CamScanner

សន្និដ្ឋានស្ថាពរដដែល និងប្តឹងសុំក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទទាំងបីនាក់ ខាងលើតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

- លោក [redacted] សំរឿន មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថាៈ ដោយសារជាប់ចោទមានចំនួន០៣នាក់ ហើយអង្គហេតុ អ្នកទាំងបីអាចមានការខុសៗគ្នា ក៏ប៉ុន្តែដើម្បីចោទប្រកាន់ជនជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោស គឺត្រូវមានភស្តុតាងបង្ហាញពីធាតុនីត្យានុកូល ខ្ញុំទទួលស្គាល់ថាមានហើយ គឺមាត្រាដែលចែងពីបទលួចមានស្ថានទម្ងន់ ប៉ុន្តែធាតុសត្យានុម័ត និងធាតុអត្តនោម័ត គឺមិនមានទេ ។ ទី១ បើយើងមើលពីភស្តុតាងដែលមានក្នុងសវនាការ គឺមានពីរនាក់ ម្នាក់ដើរតួជាដើមបណ្តឹង ម្នាក់ដើរតួជាសាក្សី ប៉ុន្តែអ្នកដើរតួជាសាក្សីក៏ជាអ្នកចូលហ៊ុនជាមួយដើមបណ្តឹងដែរ ហើយប្រសិនបើមានសំណង ក៏សាក្សីមួយរូបនេះ គាត់នឹងបានទទួលសំណងដូចគ្នាដែរ ដូចនេះ គាត់មិនមែនដើរតួជាសាក្សីទេ គាត់ជាដើមបណ្តឹងដូចគ្នា ។ ទី២ ពាក់ព័ន្ធនឹងធាតុអត្តនោម័ត ដើម្បីបង្ហាញភស្តុតាងថា ជនជាប់ចោទ ប្រព្រឹត្តបទលួចបាន លុះត្រាតែជនជាប់ចោទយល់ថារបស់នោះមិនមែនជារបស់គាត់ គឺរបស់គេ ប៉ុន្តែនៅក្នុងអង្គហេតុឃើញថា ទាំងឈ្មោះ [redacted] និងឈ្មោះ [redacted] ទទួលស្គាល់ថាដីនោះមិនមែនជាដីរបស់គាត់ទេ ដោយឈ្មោះ [redacted] ថាគាត់សុំដីពីឈ្មោះ [redacted] ធ្វើ ចំណែកឈ្មោះ [redacted] ថាមានគេចង្អុលឱ្យដីទៅគាត់ធ្វើ ហើយលោក [redacted] គឺមានរឿងទំនាស់ដីធ្លីជាមួយឈ្មោះ [redacted] ហឿ និងមានការដោះស្រាយដោយរាជ្ញាធរមានសមត្ថកិច្ច ។ ដូចនេះ មូលហេតុទី១ បើចោទប្រកាន់ថ្ងៃទី២០ គឺអត់មានសកម្មភាពនៃការដកដំឡូងទេ បើចោទនៅថ្ងៃទី១៦វិញ ការដកត្រូវមានធាតុសត្យានុម័ត និងធាតុអត្តនោម័ត ឈ្មោះ [redacted] ហឿ មិនបានទៅដកទេ ចំណែកឈ្មោះ [redacted] សីលា ក៏អត់បានទៅដកដែរ គឺទៅជួយលើក ព្រោះកម្លាំងប្រុសទើបអាចធ្វើបាន ប៉ុន្តែនិយាយពីធាតុអត្តនោម័តរបស់អ្នកទៅដក គឺគាត់ទៅដករបស់គាត់ប៉ុណ្ណោះ ដូចនេះ វាមិនមែនជាធាតុអត្តនោម័ត នៃបទលួចទេ ។ ទី២ ដើមបណ្តឹង និងសាក្សីចោទថាឈ្មោះ [redacted] ហឿ កាន់កាំបិតដេញកាប់អ្នកទាំងពីរ តាមអង្គហេតុ គឺតាមចម្លើយរបស់ដើមបណ្តឹងខ្លួនឯង គឺខ្លួននាំសមត្ថកិច្ចទៅ មិនមែនដេញកាប់ហើយរត់ទៅប្រាប់សមត្ថកិច្ចនាំមកទៀតទេ ហើយសមត្ថកិច្ចមានដល់ទៅ ៦នាក់ មិនហ៊ានធ្វើអ្វី ថាស្ពែកចាំចាប់ ដូចនេះមានភស្តុតាងជាចម្លើយរបស់ដើមបណ្តឹងខ្លួនឯងគឺមានការពាំត្រណោតខ្លួនឯង ចំណែកឯចម្លើយរបស់សាក្សីជាកូនរបស់ឈ្មោះ [redacted] ហឿ និងឈ្មោះ [redacted] ហឿ ឆ្លើយស៊ីសង្វាក់គ្នាត្រង់ថា ពេលនោះឈ្មោះ [redacted] ហឿ ស្រែកឱ្យសមត្ថកិច្ចជួយខ្លួន ។ ដូចនេះ វាអាចមានទង្វើពីរ ទី១ នៅថ្ងៃទី២០ ទី២ នៅថ្ងៃទី១៦ ចំពោះថ្ងៃទី២០ គឺគ្មានការដកដំឡូងទេ ប៉ុន្តែវាមានការចោទប្រកាន់ថា មានការទាញកាំបិតដេញកាប់ ប៉ុន្តែវាមិនសមហេតុផលត្រង់ថា អ្នកទាំងពីរចូលទៅផ្ទះរបស់គាត់ និងមានសមត្ថកិច្ចទៅជាមួយ ដូចនេះវាមិនអាចធ្វើសកម្មភាពហិង្សាអ្វីបានឡើយ ហើយបើនិយាយថា លួចមានស្ថានទម្ងន់ ទាល់តែជនជាប់ចោទបានលួចដកដំឡូង នឹងប្រើហិង្សា ទើបហៅថា លួចមានស្ថានទម្ងន់ តែនេះជារឿងពីរដាច់ដោយឡែកពីគ្នា ហើយបើមើលពី

មាឌរបស់ឈ្មោះ [redacted] ហឿ និងមាឌរបស់ឈ្មោះ [redacted] ដោយមានសមត្ថកិច្ចចំនួន៦ នាក់ផ្សេងទៀត តើសមហេតុផលឬទេ? ប៉ុន្តែចំណុចដែលសំខាន់អាចដាក់ទោសជន ដែលត្រូវគេចោទ គឺត្រូវតែមានភស្តុតាងឱ្យច្បាស់លាស់ មិនអាចមានភស្តុតាងដែលមាន ការសង្ស័យទេ រដ្ឋធម្មនុញ្ញក៏បានចែងផងដែរថា វិមតិសង្ស័យបានជាប្រយោជន៍ដល់ជន ជាប់ចោទ ដូច្នេះភស្តុតាងដែលមានការសង្ស័យមិនអាចយកមកប្រើដើម្បីដាក់ទោស មនុស្សឱ្យទៅដាក់គុកបានទេ ។ ហេតុដូច្នេះ ធាតុអង្គនោមិតក៏គ្មាន ធាតុសត្យានុមិត ក៏គ្មាន ហើយសូម្បីតែដើមបណ្តឹងខ្លួនឯងក៏ទទួលស្គាល់ថាដីនោះមិនមែនជាដីរបស់ខ្លួន នោះទេ ហើយដីនោះឈ្មោះ [redacted] ហឿ ទទួលស្គាល់ថាកំពុងមានទំនាស់ជាមួយឈ្មោះ [redacted] និង កំពុងដោះស្រាយ ហើយយោងតាមការដោះស្រាយឈ្មោះ [redacted] ហឿ ទាមទារចំនួនជាង១៥០ហិកតា តែខាងគណៈកម្មការដោះស្រាយបានថាឱ្យគាត់ចំនួន ៥៦ហិកតា ប៉ុន្តែគាត់មិនព្រម ។ វិវាទនេះមានតាំងពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០១៨ មានរយៈពេល១១ឆ្នាំមកហើយមិនទាន់ដោះស្រាយបាន ហើយភាគីខាងឈ្មោះ [redacted] មិនបង្កដោយខ្លួនឯងទេ ប៉ុន្តែគាត់ឱ្យគ្នាគាត់មកធ្វើដីដែលខ្លួនឯងដឹងថាមានទំនាស់ ហើយដើម្បីឱ្យមានការប្តឹងផ្តល់គ្នា ហើយឈ្មោះ [redacted] ហឿ ក៏ធ្លាប់ត្រូវបានដាក់ពន្ធនាគារ ។ ដូចនេះសូមក្រុមប្រឹក្សាជំនុំជម្រះ លើកលែងការចោទប្រកាន់លើអ្នកទាំងបី ។

- លោក [redacted] ចាន់ដេត មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋាន ថាៈ ក្រោយពីបានស្តាប់ការពិភាក្សាដេញដោលនាពេលសវនាការ ដោយសហភាគា បានរៀបរាប់អស់ហើយ ខ្ញុំសូមបញ្ជាក់បន្ថែមលើអង្គហេតុក្នុងរឿងនេះថាឈ្មោះ [redacted] បានធ្វើការកត់សម្គាល់ថា គាត់ជាអ្នកបានដាំដំឡូងលើដីនោះ ដោយមិនដឹងថាដីនោះជា របស់អ្នកណាឱ្យពិតប្រាកដ មួយទៀតសាក្សីក៏បានឆ្លើយបញ្ជាក់ផងដែរថា ដីនោះមាន រោងរបស់ឈ្មោះ [redacted] នៅពីមុខទៀត ហើយទាំងចម្លើយរបស់ឈ្មោះ [redacted] និងចម្លើយរបស់កូនគាត់ គឺមានរោងរបស់គាត់នៅចម្ងាយចន្លោះពី៤០០ ទៅ៥០០ម៉ែត្រ ពីមុខដីនោះ ។ ដូច្នេះ សូមក្រុមប្រឹក្សាជំនុំជម្រះពិចារណាលើអង្គហេតុនេះ ហើយចំពោះ សំណូមពរសហភាគាបានលើកឡើងរួច ហើយខ្ញុំមិនមានអ្វីទៀតទេ ។

- ក្រោយពីបានដំណើរការកិច្ចពិភាក្សាដេញដោលរួចរាល់ហើយ ។
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។
- ក្រោយពីបានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។
- ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី ។
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ។
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។
- ក្រោយពីបានពិនិត្យកំណត់ហេតុ ឯកសារភស្តុតាងនានា និងពិចារណាត្រឹមត្រូវ តាមច្បាប់ហើយ ។

## សំអាងហេតុ



ស្កេនជាមួយ CamScanner

- តាមដីកាដំណោះស្រាយលេខៈ ៦២០ ជ.ផ.រ/១៩ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០១៩ បានសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ[redacted]សីលា ឈ្មោះ[redacted]ហួង និងឈ្មោះ [redacted]ហឿ ទៅជំនុំជម្រះពីបទៈ លួចដោយហិង្សាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិ កុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

- ពិនិត្យតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]សីលា , ឈ្មោះ[redacted]ហួង និង ឈ្មោះ [redacted]ហឿ នាពេលសវនាការឃើញថាពុំមានភាពស៊ីសង្វាក់គ្នាសោះ ដោយជន ជាប់ចោទឈ្មោះ[redacted]សីលា បានបញ្ជាក់ថា "នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ ជាថ្ងៃ កើតហេតុនៃការចោទប្រកាន់ ខ្លួនមិនបានទៅដកដំឡូងទេ គឺពេលព្រឹក ខ្លួន និងប្រពន្ធ របស់ខ្លួនឈ្មោះ[redacted]ហួង បានទៅដឹកដើមចេកពីចំណុចអក្សរតេ ពីបងថ្លៃរបស់ខ្លួនយក មកផ្ទះដើម្បីដាំ មកដល់ផ្ទះវិញម៉ោងប្រហែល ៣ រសៀល ខ្លួនដឹកគោចងនៅក្រោយផ្ទះ រួចក៏ឮសំឡេងម្តាយក្មេករបស់ខ្លួនឈ្មោះ [redacted] ហឿ ស្រែកថា "ជួយផង!" ខ្លួនក៏ចេញពី កន្លែងមើលគោមកកន្លែងម្តាយក្មេក ក៏បានជួបឈ្មោះ [redacted] ដោយមានសមត្ថកិច្ច ប្រហែល ៤ ទៅ ៥ នាក់ មកជាមួយគ្នាផង ខ្លួនមិនដឹងពួកគេមកធ្វើអ្វីទេ ឃើញបែបនេះ ខ្លួនក៏ដេញចេញ ពួកគេក៏នាំគ្នាត្រលប់ទៅវិញអស់ទៅ ហើយខ្លួនក៏ត្រលប់មកផ្ទះវិញមក ។ ខ្លួនពុំមានអ្វីបញ្ជាក់ថា នៅថ្ងៃកើតហេតុ ខ្លួនបានទៅដឹកដើមចេកនោះទេ ។ សមត្ថកិច្ច ឃាត់ខ្លួននៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល៧ព្រឹក នៅពេលខ្លួន បើកឡានថ្មែដឹកដំឡូងចំនួន៣២ក្រប្ចច ប្រហែលជាង១តោន យកទៅលក់ ។ ដំឡូង នោះគឺ ខ្លួន , ប្រពន្ធ និងម្តាយក្មេករបស់ខ្លួនដកនៅចំការរបស់ខ្លួននៅក្រោយផ្ទះចម្ងាយ ប្រហែល៥០០ម៉ែត្រ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ ដកតាំងពីព្រឹក រហូតជិត ដល់ល្ងាចបានប្រហែល៣០ក្រប្ចច ចំណែកថ្ងៃទី ១៧,១៨,១៩,២០ ខ្លួនមិនបានដក ដំឡូងនោះទេ ។" ហើយជនជាប់ចោទឈ្មោះ[redacted]ហួង បានបញ្ជាក់ថា " ខ្លួនត្រូវជា ប្រពន្ធរបស់ឈ្មោះ[redacted]សីលា ។ នៅថ្ងៃទី១៧ រហូតដល់ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ ខ្លួនមិនបានទៅដកដំឡូងនោះទេ ។ នៅថ្ងៃទី១៦ ខ្លួនបានទៅដកដំឡូងជាមួយកូនតូច របស់ខ្លួន ៣ ទៅ ៤នាក់ នៅចំការរបស់ខ្លួនខាងក្រោយផ្ទះចម្ងាយប្រហែល៥០០ម៉ែត្រពី ផ្ទះ ដោយខ្លួនជាអ្នកដក កូនៗជាអ្នកជួយរើស ចំណែកប្តី របស់ខ្លួនមិនបានទៅទេ ព្រោះ រវល់ដឹកបន្លែឱ្យគេ មិនសូវនៅផ្ទះទេ រីឯម្តាយរបស់ខ្លួនក៏មិនបានទៅដែរ ហើយនៅថ្ងៃ នោះ ខ្លួនដកបានចំនួនជាង១០ក្រប្ចច និងរើសដំឡូងនៅសេសសល់ពីឈ្មោះ [redacted] លួចដកកាលពីថ្ងៃទី១៥ សរុបទាំងអស់ចំនួន ៣៣ ក្រប្ចច ដូចមានចំនួនដែលសមត្ថកិច្ច បានឃាត់ តែមិនបានយកទៅលក់ទេ រហូតដល់ថ្ងៃទី២១ ទើបខ្លួន និងប្តីយកដំឡូងនោះ ទៅលក់ ។" ចំណែកជនជាប់ចោទឈ្មោះ[redacted]ហឿ បានបញ្ជាក់ថា "ដំឡូងដែលសមត្ថកិច្ច ឃាត់មានចំនួន៣២ក្រប្ចច បានមកពីកូនរបស់ខ្លួនឈ្មោះ ស្រីហួង និងឈ្មោះ[redacted]សីលា និងអ្នកផ្សេងទៀតខ្លួនមិនចាំ បានទៅដកនៅចំការជាដីរបស់ខ្លួនខាងក្រោយផ្ទះ កាលពី



ស្កេនជាមួយ CamScanner

ថ្ងៃទី១៦ និងតាំងពីមុនហូរហែរហូតមក ប៉ុន្តែនៅថ្ងៃទី២០ មិនបានដកទេ ចំណែកខ្លួន មិនបានទៅដកនោះទេ ហើយក៏មិនបានឃើញអ្នកណាខ្លះដកនោះដែរ គឺគ្រាន់តែឃើញពួកគេបានទៅ រួចពេលខ្លួនទៅមើលឃើញមានចំនួន៣២ការុង ៗ ។

- ចម្លើយរបស់ជនជាប់ចោទទាំងបីនាក់នាពេលសវនាការទៀតសោត គឺផ្ទុយទៅនឹងកំណត់ហេតុចម្លើយរបស់ជនជាប់ចោទ នៅក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងដំណាក់កាលចៅក្រមស៊ើបសួរ ដែលជាហេតុមិនអាចឱ្យតុលាការជឿជាក់ថាអង្គហេតុ ដែលជនជាប់ចោទបានអះអាង គឺជាការពិតឡើយ ។

- តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដែលបានបញ្ជាក់ថា "ដំឡូងជារបស់ខ្លួនជាអ្នកដាំ ចំណែកដីនោះ គឺខ្លួនសុំឈ្មោះ [redacted] ដាំ ។ ខ្លួនទើបតែដាំមួយឆ្នាំប៉ុណ្ណោះ គឺដាំកាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ ។ ជនជាប់ចោទបានទៅដកដំឡូងនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ មានគ្នាបីនាក់ គឺអ្នកទាំងបីដែលកំពុងមានវត្តមាននេះ ហើយខ្លួនឃើញដោយផ្ទាល់ភ្នែក ។ ខ្លួនមិនដឹងថាដីនោះមានទំនាស់នោះទេ ព្រោះដីរបស់គេមានម្ចាស់ ។ ដីនោះមានគេដាំដំឡូងពីមុនមក ប៉ុន្តែមិនមែនពួកគាត់ជាអ្នកដាំទេ គឺអ្នកផ្សេងទៅថៃបាត់ហើយ ហើយផ្អាក២ឆ្នាំ ខ្លួនក៏សុំគេដាំទៅ ។ ខ្លួនមិនឃើញមានផ្ទះ ឬ រោងនៅក្បែរនោះទេ ។ ខ្លួនដាំដំឡូងលើដីទំហំ៥ហិចតា ហើយត្រូវជនជាប់ចោទលួចដកអស់ប្រមាណជាង៣០ក្របួច ដែលដាក់លើឡាននោះ ចំពោះទំហំដីមិនដឹងអស់ទំហំប៉ុន្មានទេ ព្រោះមិនបានវាស់ ។" ឃើញថាការអះអាងរបស់ដើមបណ្តឹងមានភាពស៊ីសង្វាក់គ្នាទៅនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ដែលអាចឱ្យតុលាការជឿជាក់ថា ជនជាប់ចោទទាំងបីនាក់ពិតជាបានធ្វើសកម្មភាពទៅដកដំឡូងរបស់ដើមបណ្តឹងដែលបានដាំក្នុងចម្ការស្ថិតនៅភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ប្រាកដមែន ប៉ុន្តែសកម្មភាពរបស់ជនជាប់ចោទ គឺពុំបានប្រើហិង្សាដូចដើមបណ្តឹងបានអះអាងថា "ជនជាប់ចោទបានទាញកាំបិតដេញកាប់ពួកខ្លួន" នោះទេ ពីព្រោះថា នៅពេលកើតហេតុនោះ គឺមានសមត្ថកិច្ចទៅជាមួយដើមបណ្តឹងដែរ ហើយប្រសិនបើជនជាប់ចោទប្រើហិង្សាមែននោះច្បាស់ជាសមត្ថកិច្ចធ្វើការឃាត់ខ្លួនហើយ ។ សរុបជារួម តុលាការយល់ឃើញថា អំពើរបស់ជនជាប់ចោទទាំង៣នាក់ គឺជាអំពើលួច (លួចដកដំឡូង) ដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ ,៣៥៦ នៃក្រមព្រហ្មទណ្ឌ ពុំមែនជាអំពើលួចដោយហិង្សាមានស្ថានទម្ងន់ទោសនោះទេ គប្បីតុលាការធ្វើការកែប្រែបទចោទឱ្យបានត្រឹមត្រូវវិញ ។

- ជនជាប់ចោទឈ្មោះ [redacted] សីលា ឈ្មោះ [redacted] ហួង និងជនជាប់ចោទឈ្មោះ [redacted] ហឿ ជានីតិជនដែលមានកាយសម្បទាបរិបូរណ៍ ដោយពុំមានសញ្ញាណាមួយបញ្ជាក់ថាជនជាប់ចោទមានបញ្ហាវិបល្លាសស្មារតីនាពេលប្រព្រឹត្តបទល្មើស ដែលនាំឱ្យជនជាប់ចោទរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ដូចនេះឃើញថា ជនជាប់ចោទ គឺជាជនដែលអាចគិតពិចារណាបានច្បាស់លាស់ពីអំពើ និងបច្ច័យដែលកើតមានឡើងដោយសារអំពើរបស់ខ្លួន តែជននេះនៅតែប្រព្រឹត្តបទល្មើស ហើយលក្ខខណ្ឌគតិយុត្តតម្រូវឱ្យទទួល



ស្កេនជាមួយ CamScanner

ខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ដែលអំពើនោះចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ ។

- អំពើប្រព្រឹត្តរបស់ជនជាប់ចោទបានធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ, សន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និងខុសនឹងច្បាប់រដ្ឋជាធរមាន ។

- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សីលា ឈ្មោះ [redacted] ហួង និងជនជាប់ចោទឈ្មោះ [redacted] ហឿ ពីបទៈ អំពើលួច ប្រព្រឹត្តនៅភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

- ជនជាប់ចោទឈ្មោះ [redacted] សីលា ឈ្មោះ [redacted] ហួង និងឈ្មោះ [redacted] ហឿ ទើបតែប្រព្រឹត្តបទល្មើសលើកទី១ ហើយមិនទាន់មានការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារជាស្ថាពររយៈពេល០៥ឆ្នាំមុនអំពើល្មើស ដូចនេះ គប្បីតុលាការផ្តល់ឱ្យជនជាប់ចោទបានទទួលនូវការព្យួរទោសតាមបញ្ញត្តិមាត្រា១០៦ មាត្រា១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានចូលមកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងបានទាមទារសំណងការខូចខាត និង សំណងជំងឺចិត្ត ពីជនជាប់ចោទចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក ដូចនេះ គប្បីតុលាការលើកយកមកធ្វើការពិនិត្យពិចារណាអំពីសំណងការខូចខាត និងសំណងជម្ងឺចិត្តនេះ តាមព្យសនកម្មជាក់ស្តែង ។

## <u>**ហេតុដូច្នេះសម្រេច**</u>

១- កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] សីលា , ឈ្មោះ [redacted] ហួង , និងឈ្មោះ [redacted] ហឿ ពីបទ លួចដោយហិង្សាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ មកបទ អំពើលួច ប្រព្រឹត្តនៅភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

២-ផ្តន្ទាទោសលើ ៖

ក/ ឈ្មោះ [redacted] សីលា ហៅ ឡា ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ (ដែលមានសាវតារជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២ ០០០ ០០០ (ពីរលាន) រៀល តែទោសនេះត្រូវអនុវត្តៈ

- អនុវត្តទោសពន្ធនាគារគិតចាប់ពីថ្ងៃឃុំខ្លួន ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ រហូតដល់ថ្ងៃបាននៅក្រៅឃុំ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ។

- ទោសពន្ធនាគារដែលនៅសល់ និងទោសពិន័យជាប្រាក់ត្រូវព្យួរការអនុវត្ត ។



ស្កេនជាមួយ CamScanner

ខ/ ឈ្មោះ [redacted] ហួង ភេទស្រី អាយុ២៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ (ដែលមានសាវតារជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២ ០០០ ០០០ (ពីរលាន) រៀល តែទោសទាំងអស់នេះត្រូវព្យួរការអនុវត្ត ។

គ/ ឈ្មោះ [redacted] ហឿ ភេទស្រី អាយុ៥៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ (ដែលមានសាវតារជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២ ០០០ ០០០ (ពីរលាន) រៀល តែទោសទាំងអស់នេះត្រូវព្យួរការអនុវត្ត ។

ពីបទៈ អំពើលួច ប្រព្រឹត្តនៅភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៣- បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] សីលា, ឈ្មោះ [redacted] ហួង និងឈ្មោះ [redacted] ហឿ រួមគ្នាសងសំណងការខូចខាត និងសំណងជម្ងឺចិត្តចំនួន ១០ ០០០ ០០០ (ដប់លាន) រៀល ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទាមទារលើសពីនេះបដិសេធចោល ។

៤- សេចក្តីសម្រេចនេះប្រកាសដោយចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃចន្ទ ០៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅបាត់ដំបង, ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជីសវនាការ

[redacted]



ស្កេនជាមួយ CamScanner